**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ១២៧ ប្រក

ថ្ងៃអង្គារ ២រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០

# ប្រកាស
# ស្ដីពី
# វិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១._**

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធានសុវត្ថិភាពសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍និងអ្នកបកប្រែភាសាបន្ត ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ លើកកម្ពស់សុវត្ថិភាពទេសចរ និងបង្កើតទំនុកចិត្តជូនទេសចរធ្វើដំណើរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

... E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ ២._**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត។

**ប្រការ ៣._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤._**

មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តមានកាតព្វកិច្ចអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដូចខាងក្រោម៖

ក. ត្រូវណែនាំដល់ទេសចរជាតិ-អន្តរជាតិពីវិធានសុវត្ថិភាពរបស់ក្រសួងសុខាភិបាលស្តីពីការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ដោយផ្តោតលើគោលការណ៍ពាក់ម៉ាស់ លាងដៃ វាស់កម្តៅ និងរក្សាគម្លាត មុនពេលផ្តល់សេវាកម្ម

ខ. ត្រូវពាក់របាំងការពារមុខ ឬម៉ាស់ ក្នុងអំឡុងពេលផ្តល់សេវាកម្ម

គ. ត្រូវដាក់តាមខ្លួននូវម៉ាស់ ទឹកអាល់កុល ឬទឹកសម្លាប់មេរោគ និងឧបករណ៍វាស់កម្តៅ(បើមាន) សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬ/និងចែកជូនទេសចរដែលជាអ្នកទទួលសេវាកម្មក្នុងករណីចាំបាច់

ឃ.ត្រូវសម្អាតដៃជាមួយទឹកអាល់កុល ឬទឹកសម្លាប់មេរោគភ្លាមៗរៀងរាល់ពេលដែលប៉ះពាល់ផ្ទាល់ជាមួយទេសចរ និងត្រូវសម្អាតដៃឱ្យបានញឹកញាប់

ង. ត្រូវបន្តអនុវត្តឱ្យបានត្រឹមត្រូវតាមក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត

ច. ត្រូវប្រើប្រាស់ឧបករណ៍ឧគ្ឃោសនាសព្ទ ករណីទទួលក្រុមទេសចរលើសពី១០នាក់

ឆ. ត្រូវរាយការណ៍ទៅការីទេសចរណ៍របស់ខ្លួន ឬលេខទំនាក់ទំនងទាន់ហេតុការណ៍១១៥ ក្នុងករណីសង្កេតឃើញទេសចរមានអាការដូចជា គ្រុនក្តៅ ក្អក កណ្តាស់ រលាកបំពង់ក ហៀរសំបោរ ឬពិបាកដកដង្ហើម។

**ប្រការ ៥._**

វិធានសុវត្ថិភាពទេសចរណ៍ដែលមានចែងក្នុងប្រការ៤នៃប្រកាសនេះ ត្រូវចាត់ទុកជាលក្ខខណ្ឌបន្ថែមក្នុងការស្នើសុំ ឬបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ឬបណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្ត។ ការមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមវិធានទាំងនេះ នឹងក្លាយជាកម្មវត្ថុនៃព្យួរអាជ្ញាបណ្ណទេសចរណ៍ ឬបណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្តជាបន្ទាន់ ស្របតាមមាត្រា៤៤ កថាខណ្ឌទី២នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ ៦._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលបានបំពេញគ្រប់វិធានសុវត្ថិភាពទេសចរណ៍ក្នុងប្រការ៤នៃប្រកាសនេះ នឹងទទួលបានឡាបិលមគ្គុទ្ទេសក៍ទេសចរណ៍សុវត្ថិភាពដូចបានកំណត់ក្នុងឧបសម្ព័ន្ធ១នៃប្រកាសនេះ។

អ្នកបកប្រែភាសាបន្តដែលបានបំពេញគ្រប់វិធានសុវត្ថិភាពទេសចរណ៍ក្នុងប្រការ៤នៃប្រកាសនេះនឹងទទួលបានឡាបិលអ្នកបកប្រែភាសាបន្តសុវត្ថិភាពដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ។

ឡាបិលមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តដែលមានសុវត្ថិភាពមានទម្រង់ជាស្លាកសញ្ញាសម្គាល់។

**ប្រការ ៧._**

នីតិវិធីអនុវត្តវិធានសុវត្ថិភាពសម្រាប់អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តត្រូវកំណត់ដោយសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ ៨._**

ក្រុមការងារត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានីខេត្តជាយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត។

**ប្រការ ៩._**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សហព័ន្ធទេសចរណ៍កម្ពុជា
- សមាគមវិជ្ជាជីវៈទេសចរណ៍កម្ពុជា
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ១

## នៃប្រកាសលេខ ១៤៨ ប្រក ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ស្ដីពីវិធានសុវត្ថិភាព ទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍និងអ្នកបកប្រែភាសាបន្ត

## ឡាបិលមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានសុវត្ថិភាពប្រឆាំងនឹងកូវីដ-១៩ (COVID-19)

# វិធានសុវត្ថិភាពទេសចរណ៍

# TOURISM SAFETY MEASURES

## ឧបសម្ព័ន្ធ២
## នៃប្រកាសលេខ ១២៨ ប្រក ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍និងអ្នកបកប្រែភាសាបន្ទ

### ឡាបិលអ្នកបកប្រែភាសាបន្ទ ដែលមានសុវត្ថិភាពប្រឆាំងនឹងកូវីដ-១៩ (COVID-19)

## វិធានសុវត្ថិភាពទេសចរណ៍
## TOURISM SAFETY MEASURES